**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អាជ្ញាធរជាតិអប្សរា
APSARA

លេខ០៤០/២០ មសអ.លជ៧)

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកឱ្យដំណើរការទីតាំងថ្មីរបស់មជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា ស្ថិតនៅភូមិមណ្ឌលបី សង្កាត់ស្លក្រាម ក្រុង-ខេត្តសៀមរាប

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជន ជាពិសេសប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរទាំងអស់ជ្រាបថា ក្នុងគោលបំណងលើកកម្ពស់ និងពង្រីកការផ្តល់សេវាសាធារណៈរបស់អាជ្ញាធរជាតិអប្សរា ស្របតាមយន្តការច្រកចេញ-ចូលតែមួយឱ្យមានប្រសិទ្ធភាព និងកាន់តែខិតជិតប្រជាពលរដ្ឋ និងអ្នកប្រើប្រាស់សេវានានាពាក់ព័ន្ធតំបន់រមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរានឹងបើកឱ្យដំណើរការជាផ្លូវការទីតាំងមជ្ឈមណ្ឌលសេវាកម្មថ្មីមួយកន្លែងទៀត ស្ថិតនៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប (អតីតបញ្ជរលក់ប័ណ្ណចូលទស្សនារមណីយដ្ឋានអង្គរ) តាមបណ្តោយផ្លូវហ្វាលដីហ្វាលឆ្ពោះទៅប្រាសាទអង្គរវត្ត ចាប់ពីថ្ងៃចន្ទ ១៣រោច ខែចេត្រ ឆ្នាំជូត ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០នេះតទៅ។ ចំពោះការដាក់ពាក្យស្នើសុំសេវាសាធារណៈផ្សេងៗក្នុងតំបន់អង្គរ អ្នកប្រើប្រាស់អាចស្វែងរកនៅ ទីតាំងដូចខាងក្រោម៖

១- ស្នាក់ការកណ្តាលអាជ្ញាធរជាតិអប្សរា ស្ថិតនៅភូមិបង្គោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប

២- ភូមិមណ្ឌលបី សង្កាត់ស្លក្រាម ក្រុងសៀមរាប

៣- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលក្រុងសៀមរាប

៤- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកពួក

៥- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកអង្គរធំ

៦- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកបន្ទាយស្រី

៧- និងតាមរយៈក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំស្រុក-ក្រុងទាំង៥ (ចំពោះការស្នើសុំជួសជុលតូចតាច)

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបជាព័ត៌មាន។ សូមទាក់ទងតាមរយៈទូរស័ព្ទ+(៨៥៥)៦៣ ៧៦ ៥៥ ៧៧ /អ៊ីម៉ែល៖ sca_apsara@yahoo.com។

ថ្ងៃពុធ...៤...រោច......ខែចេត្រ...ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

សៀមរាប ថ្ងៃទី ១៥ ខែមេសា.. ឆ្នាំ២០២០

**អាជ្ញាធរជាតិអប្សរា**



Scanned with CamScanner